ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

សេចក្តីប្រកាសព័ត៌មាន

**«សិក្ខាសាលាស្តីពីវឌ្ឍនភាពការងារការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣»**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០២៣ - **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុង «សិក្ខាសាលាវឌ្ឍនភាពការងារការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣» នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលបានរៀបចំឡើងដោយក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅសណ្ឋាគារ Hyatt Regency Phnom Penh តាមទម្រង់ Hybrid។

សិក្ខាសាលានេះមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងតំណាងវិស័យឯកជន សរុបប្រមាណ ៤០០ នាក់។ សិក្ខាសាលាខាងលើមានគោលបំណង៖ ១) តាមដាន និងបូកសរុបសមិទ្ធផលការងារការទូតសេដ្ឋកិច្ចប្រចាំឆ្នាំ២០២២ និង២) ប្រមូលធាតុចូលបន្ថែមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួង និងជាមួយវិស័យឯកជន ក្នុងវិស័យការទូតសេដ្ឋកិច្ច។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានវាយតម្លៃខ្ពស់លើការរៀបចំសិក្ខាសាលានាពេលនេះ និងបានកោតសរសើរលើកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច ដែលសម្រេចបានសមិទ្ធផលធំៗនាពេលកន្លងមក។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់ពីសារៈសំខាន់ នៃភាពជាដៃគូរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធជាមួយវិស័យឯកជនក្នុងការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច និងបានជំរុញឱ្យកិច្ចសហប្រតិបត្តិការនេះកាន់តែមានប្រសិទ្ធភាព ដើម្បីចូលរួមចំណែកលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាតិ។ ក្នុងនោះផងដែរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ដើម្បីសម្រេចការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២៣ និងទិសដៅបន្ត។

កម្មវិធីនេះមានការធ្វើបទបង្ហាញស្តីពី ១) សមិទ្ធផលធំៗដែលក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច និងស្ថានតំណាងកម្ពុជានៅបរទេសសម្រេចបានក្នុងឆ្នាំ២០២២ ២) ផែនការអភិវឌ្ឍន៍ធនធានមន្ត្រីការទូតក្នុងវិស័យការទូតសេដ្ឋកិច្ច របស់វិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ និង ៣) ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងកសិកម្ម៕

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh